# តើការរៀនសូត្រដែលមានប្រសិទ្ធភាពមានន័យដូចម្តេច?

ដោយឡេងឆាយ

## គំរូវការរៀនសូត្រនិងសំណូមពររៀនសូត្រ

- តំរូវការរៀនសូត្រជាកង្វះខាតផ្នែកចំណេះដឹង ជំនាញ និងអាកប្បកិរិយា ដែលត្រូវអភិវឌ្ឍបន្ថែម
- តំរូវការរៀនសូត្រចេញមកពីស្ថានភាព ឬកិច្ចការដែលធ្វើមិនទាន់បានល្អ ឬជាចំនុចខ្សោយ
- សំណូមពររៀនសូត្រ ជាព្រឹត្តិការណ៍រៀនសូត្រមួយ ដែលបុគ្គលិកចង់ចូលរួម ប៉ុន្តែមិនចាំបាច់មានបំណងក្នុងការលុបបំបាត់ចំនុចខ្សោយ ឬដោះស្រាយបញ្ហាណាមួយរបស់បុគ្គលិកឡើយ។

## ការវាស់វែងប្រសិទ្ធភាពនៃការរៀនសូត្រ

- ព្រឹត្តិការណ៍រៀនសូត្រអាចប៉ាន់ប្រមាណបានបន្ទាប់ពីការរៀនសូត្រមួយបានបញ្ចប់ភ្លាម
- ព្រឹត្តិការណ៍រៀនសូត្រដែលល្អ (ដូចជាមានកន្លែងល្អ ដោយមានម៉ាស៊ីនត្រជាក់មានអាហារសំរន់ និងភេសជ្ជៈល្អ មានឯកសារចែកជូនច្រើន គ្រូផ្តល់ចំលើយច្រើន។ល។) មិនមែនមានន័យជាស្វ័យប្រវត្តិថាការរៀនសូត្រនោះមានប្រសិទ្ធភាពដែរ។
- ការរៀនសូត្រមួយមានប្រសិទ្ធភាពលុះត្រាតែ វាបានដោះស្រាយនូវតំរូវការរៀនសូត្រដែលបានកំនត់ ហើយវាបានសំរេចនូវទិន្នផល ឥទ្ធិពលមធ្យម និងឥទ្ធិពលរយៈពេលវែង នៃការរៀនសូត្រ
- ឥទ្ធិពលមធ្យម និងឥទ្ធិពលរយៈពេលវែង នៃការរៀនសូត្រ មិនអាចសំរេចបានក្រោយពេលព្រឹត្តិការណ៍រៀនសូត្រភ្លាមៗនោះទេ។




This learning article shared by Cambodian Learning Facilitators (www.camlefa.org). All rights reserved.